# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA WHC 37th 2013

UNESCO United Nations Educational, Scientific and Cultural Organization · World Heritage Convention

ភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៣

### សេចក្តីប្រកាសព័ត៌មាន
### កម្ពុជាជាប្រធាន និងម្ចាស់ផ្ទះរៀបចំសម័យប្រជុំពេញអង្គលើកទី ៣៧
### នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក
### ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣

កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេស ៩នៅអាស៊ីដែលមានឱកាសធ្វើជាប្រធាន និងជាម្ចាស់ផ្ទះរៀបចំសម័យប្រជុំពេញអង្គលើកទី៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដែលនឹងប្រព្រឹត្តិទៅ ពីថ្ងៃទី១៦ ដល់ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០១៣។ ពិធីបើកនឹងប្រារព្ធធ្វើជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាល្ងាចថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១៣ នា វិមានសន្តិភាព នៅទីក្រុងភ្នំពេញ។

គណៈប្រតិភូប្រមាណ ១៣០០ នាក់ មកពីប្រទេសចំនួនជាង ១២០ ប្រទេស ដែលជាសមាជិកអនុសញ្ញា ឆ្នាំ១៩៧២ ស្តីពីការការពារ បេតិកភណ្ឌពិភពលោកវប្បធម៌ និងធម្មជាតិ នៃអង្គការយូណេស្កូ នឹងចូលរួមក្នុងព្រឹត្តិការណ៍ជាសកលនេះ។ ទីក្រុងភ្នំពេញ នឹងក្លាយជាទីក្រុងប្រវត្តិសាស្ត្រ នៃការចុះបញ្ជីសម្បត្តិបេតិកភណ្ឌជាតិរបស់ប្រទេសនានាក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលបច្ចុប្បន្ន នេះមានសម្បត្តិបេតិកភណ្ឌពិភពលោកសរុបចំនួន ៩៦២ រួចជាស្រេច។ សម័យប្រជុំពេញអង្គនីមួយៗមានភារកិច្ចៈ

១-ធ្វើអត្តសញ្ញាណសម្បត្តិវប្បធម៌ និងធម្មជាតិដែលមានតម្លៃជាសាកល និងមិនអាចកាត់ថ្លៃបាន ដោយផ្អែកលើសំណើរបស់រដ្ឋភាគី ដើម្បីទទួលបានការការពារ អនុលោមតាមអនុសញ្ញា និងដើម្បីចុះក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក។

២-ត្រួតពិនិត្យស្ថានភាពអភិរក្សនៃសម្បត្តិវប្បធម៌ដែលបានចុះបញ្ជីជាបេតិកភ័ណ្ឌពិភពលោក ដោយសហការជាមួយរដ្ឋភាគី និងសម្រេចថាតើមានសម្បត្តិវប្បធម៌ណាដែលត្រូវចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងស្ថានភាពគ្រោះថ្នាក់ ឬដកចេញពីបញ្ជីនេះ ព្រមទាំងសម្រេចថាតើសម្បត្តិវប្បធម៌ណាមួយដែលត្រូវលុបចេញពីបញ្ជីបេតិកភណ្ឌពិភពលោក។

៣-ពិនិត្យមើលសំណើសុំជំនួយហិរញ្ញវត្ថុអន្តរជាតិដែលគាំទ្រថវិកាដោយមូលនិធិបេតិកភ័ណ្ឌពិភពលោក។

អ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលចាប់អារម្មណ៍នឹងព្រឹត្តិការណ៍នេះត្រូវបានអញ្ជើញឱ្យបំពេញបែបបទចុះឈ្មោះយកព័ត៌មានតាមរយៈក្រសួងព័ត៌មាន ដោយធ្វើទំនាក់ទំនងជាមួយៈ

លោក ពូ ពិសិទ្ធិ ទូរស័ព្ទ: (៨៥៥)១៧ ៨៩៩ ០០៧ - Email : poue_piseth@yahoo.com
ឬតាមប្រព័ន្ធអេឡិចត្រូនិចតាមរយៈគេហទំព័រ:
http://www.whc37cambodia2013.kh/mediainfo/73.html

និង ក៏ត្រូវបានអញ្ជើញចូលរួមស្តាប់ការផ្តល់ព័ត៌មានទូទៅសម្រាប់ការប្រព្រឹត្តទៅនៃសម័យប្រជុំនាថ្ងៃ អាទិត្យ ទី១៦ ខែមិថុនា ឆ្នាំ២០១៣ វេលា ម៉ោង ១០:០០ ព្រឹក នៅសាលសន្និសីទសារព័ត៌មាន B នាវិមានមិត្តភាព!

សម្រាប់ព័ត៌មានពិស្តារ:
សូមទាក់ទង អ្នកនាំពាក្យនៃសម័យប្រជុំពេញអង្គលើកទី ៣៧:

| |
|---|
| 1- **លោក ខឹម សុវណ្ណារុំ** (ភាសាខ្មែរ-បារាំង)<br>ទូរស័ព្ទ: (៨៥៥) ០១២ ៥១៨ ៨៨៥<br>Email: media-center@whc37cambodia2013.kh |
| 2- **លោក ឯក ថា** (ភាសាខ្មែរ-អង់គ្លេស)<br>ទូរស័ព្ទ: (៨៥៥) ០១២ ៩០៦ ៥៦៣<br>Email: media-center@whc37cambodia2013.kh |
| 3- **លោកស្រី ថៅ ស៊ុនកិរិយា** (ភាសាបារាំង)<br>ទូរស័ព្ទ: (៨៥៥) ០១៧ ៥៦៩ ០០១<br>Email: media-center@whc37cambodia2013.kh |